# ឯកសារស្ដីអំពី យុទ្ធសាស្ត្រទំនាក់ទំនង

## គម្រោងបង្កើនសមត្ថភាពឌីជីថលក្នុងវិស័យអប់រំ ឆ្នាំ២០២៣ ដល់ ២០២៦

យុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់គម្រោង "បង្កើនសមត្ថភាពឌីជីថលក្នុងវិស័យអប់រំ" មានគោលបំណងបង្ហាញឱ្យឃើញនូវចំណុចសំខាន់ៗអំពីមូលហេតុ វិធីសាស្ត្រ និងធាតុនៃគម្រោងនេះ ទៅកាន់ក្រុមការងារគម្រោង ម្ចាស់ជំនួយ អ្នកផ្តួចផ្តើមគំនិត អ្នកពាក់ព័ន្ធផ្សេងទៀត និងសាធារណៈជនទាំងអស់ប្រកបដោយប្រសិទ្ធភាព។ គោលដៅនៃយុទ្ធសាស្ត្រនេះ គឺដើម្បីបង្ហាញលទ្ធផលនិងផលជះវិជ្ជមាន អំឡុងដំណើរការរយៈពេលបីឆ្នាំរបស់គម្រោង និងដើម្បីគាំទ្រសកម្មភាពគម្រោងក្នុងការលើកកម្ពស់ការយល់ដឹង ឬការលើកស្ទួយយ៉ាងសកម្ម ដើម្បីបង្កើនកិត្តិសព្ទរបស់អង្គភាពស្ថាប័នពាក់ព័ន្ធ រួមមានម្ចាស់ជំនួយនៃគម្រោង ក្នុងចំណោមសាធារណជនកម្ពុជា ជាពិសេសទស្សនិកជនខ្មែរដែលពាក់ព័ន្ធទាំងអស់។

# Documentation of Communication Strategy

## Improve Digital Competency in Education Project 2023 - 2026

The communication strategy for the project "Improve Digital Competency in Education" aims to effectively convey the key messages of why, how, and what of the project to the project team, donors, initiators, other stakeholders and the public. The strategy's goal is to positively highlight project's results and impacts over the course of the project's three-year life cycle and to support project activities in promoting awareness or advocacy, in order to raise profile of the organization, including donors of the project, among the Cambodian public, especially relevant Cambodian audiences.



WOORI BANK ChildFund Korea ChildFund Cambodia Teach For Cambodia

## អំពីគម្រោង
## About Project

គម្រោងបង្កើនសមត្ថភាពឌីជីថលក្នុងវិស័យអប់រំ ឆ្នាំ២០២៣ ដល់ ២០២៦ នឹងនាំឱ្យមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នូវសមត្ថភាពឌីជីថលក្នុងសាលារៀននៅកម្ពុជា និងផ្តល់ឱកាសស្មើគ្នាដល់សិស្សានុសិស្ស សម្រាប់ធ្វើការអភិវឌ្ឍខ្លួនក្នុងយុគសម័យឌីជីថល។

ធនាគារ អ៊ូរី និង អង្គការឆាលហ្វាន កម្ពុជា សហការគ្នា បង្កើនសមត្ថភាពឌីជីថលក្នុងវិស័យអប់រំជាមួយ រដ្ឋាភិបាល តាមរយៈការផ្តល់ជូននូវលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ គម្រោងនេះមានគោលបំណងបំពាក់នូវជំនាញកុំព្យូទ័រជាមូលដ្ឋាន អក្ខរកម្មហិរញ្ញវត្ថុ និងចំណេះដឹងអំពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញ ដល់សិស្សានុសិស្សជាង ២៤,០០០ នាក់ អ្នកចូលរួមដោយផ្ទាល់សរុបប្រមាណ ៦៤,៦១៣ នាក់ និងចូលរួមដោយប្រយោល សរុបប្រមាណចំនួនជាង ៦០,០០០ នាក់ រួមមានគ្រូបង្រៀន ឪពុកម្តាយ និងមន្ត្រីរាជការ ។ វិធីសាស្ត្រប្រកបដោយភាពគ្រប់ជ្រុងជ្រោយមួយនេះ នឹងបង្កើតបាននូវធនធានមនុស្សជំនាន់ក្រោយ ពោរពេញដោយទេពកោសល្យ ត្រៀមខ្លួនចូលរួម ក្នុងពិភពឌីជីថល។

អង្គការឆាលហ្វាន កម្ពុជា នឹងសហការជាមួយរដ្ឋាភិបាល និងអង្គការជំនាញក្នុងស្រុក អង្គការបង្រៀនដើម្បីកម្ពុជា ក្នុងការអនុវត្តគម្រោងនេះ។ ចីរភាព និងផលជះ របស់គម្រោងនឹងត្រូវបានធានាតាមរយៈបណ្តាញកិច្ចសហប្រតិបត្តិការ ការបង្កើនសមត្ថភាព និងការចូលរួមរបស់រដ្ឋាភិបាល និងសហគមន៍។

The Improve Digital Competency in Education Project 2023 - 2026 will revolutionize digital competency in Cambodian schools and provide equal opportunities for students to thrive in the digital age.

Woori Bank and ChildFund Cambodia join hands to improve digital competency in education with Government by providing access to cutting-edge technology. The initiative aims to equip more than 24,000 students with total estimated direct participants will be 64,613 and approximately 60,000 indirect participants included teachers, parents and government officers with fundamental computer skills, financial literacy, and online safety knowledge. This holistic approach will create a generation of talented global citizens prepared to navigate the digital landscape.

ChildFund Cambodia will collaborate with a local expert NGO Teach for Cambodia and Government to implement the project. Through collaborative networking, capacity building, and government and community engagement, the project's sustainability and impact will be ensured.

## សកម្មភាពសំខាន់ៗ
## Important Activities:

- គម្រោងនេះបានផ្តល់សិទ្ធិឱ្យសាលារៀនគោលដៅ ដើម្បីបង្ហាញអំពីការសិក្សាបែបឌីជីថល ដែលមានដំណើរទៅយ៉ាងល្អ ជាមួយនឹងការពង្រឹងអភិបាលកិច្ចក្នុងការគ្រប់គ្រងសាលារៀន។
  Empowering target schools demonstrate well-functioning digital learning spaces with strengthened governance of school management.

- ផ្តល់នូវគំនិតថ្មីៗដល់ប្អូនៗដែលនៅក្នុងសាលាគោលដៅ ជាមួយនឹងផ្នែកឌីជីថល ផ្នែកហិរញ្ញវត្ថុ និងការការពារតាមប្រព័ន្ធអនឡាញ ដែលប្អូនៗត្រូវការសម្រាប់សតវត្សទី ២១។
  Equipping young minds in target schools with the digital compass, financial toolkit, and online shield they need to navigate the 21st century.

- ការបង្កើតការយល់ដឹងដល់សាធារណៈ លើអក្ខរកម្មឌីជីថល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងសុវត្ថិភាពតាមអនឡាញនៅក្នុងសហគមន៍ និងថ្នាក់ជាតិ។
  Increasing public awareness on digital literacy, financial literacy, and online safety at community and national level.

- ការរៀបចំ បន្ទប់សិក្សាធម្មតា ឲ្យទៅជាបន្ទប់សិក្សាបែបឌីជីថលដោយមានការបំពាក់នូវបច្ចេកវិទ្យានិងឧបករណ៍ទំនើបៗ ដល់សាលាគោលដៅ។
  Transforming ordinary classrooms into digital labs equipped with cutting-edge technology and tools to empower students in target schools.

- ការរៀបចំសៀវភៅសិក្សា និងការបណ្តុះបណ្តាលរហូតដល់ការធ្វើតេស្តកុំព្យូទ័រសាកល្បង ដែលមានការគាំទ្រដោយរាជរដ្ឋាភិបាលដែលផ្តល់ជូនសាលាគោលដៅ និងសហគមន៍ ជាមួយនឹងជំនាញឌីជីថល ហិរញ្ញវត្ថុ និងសុវត្ថិភាពតាមអនឡាញ។
  From textbooks and training modules to pilot computer tests, government-backed initiatives empower communities with digital, financial, and online safety skills.

- គម្រោងនេះបានផ្តល់ឱ្យកុមារ និងយុវជន បានចូលទៅក្នុងពិភពឌីជីថលតាមរយៈព្រឹត្តិការណ៍សុវត្ថិភាពតាមអនឡាញ និងការផ្តួចផ្តើមគំនិតដើម្បីបង្កើតជំនាញ ICT។
  Empowering children and youth in the digital world through online safety events and ICT skill-building initiatives.

## ទីតាំង
## Location

តាមរយៈអង្គការឆាលហ្វាន កូរ៉េ គម្រោងដែលមានរយៈពេលបីឆ្នាំនេះ នឹងពង្រឹងការអប់រំអំពីឌីជីថល ក៏ដូចជា ហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងសាលារៀនចំនួន ២១ ដែលត្រូវបានជ្រើសរើស យ៉ាងម៉ត់ចត់ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ធំ។

Through ChildFund Korea ,the 3 years project will enhance digital education and infrastructure in 21 carefully selected schools across Phnom Penh, Kandal, and Kampong Thom provinces.




## ២១ សាលារៀន
## 21 Schools



ភ្នំពេញ
Pnhom Penh

កំពង់ធំ
Kompong Thom

កណ្តាល
Kandal

## អ្នកចូលរួម
## Participants



| កុមារ | យុវជន | ឪពុកម្តាយ និងអ្នកថែទាំ | គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន | សាធារណជនទូទៅ | ម្ចាស់ជំនួយ | បុគ្គលិកអប់រំថ្នាក់ខេត្ត | រដ្ឋាភិបាល |
|---|---|---|---|---|---|---|---|
| Children | Youth | Parents & Caregivers | SMC & teachers | General public audience | Donors | Provincial of Educators | Government |

## គោលបំណងនៃការទំនាក់ទំនង
## Communication Objective

ដើម្បីលើកកម្ពស់ការយល់ដឹងអំពីចំណេះដឹងផ្នែកឌីជីថល និងហិរញ្ញវត្ថុ រួមទាំងសុវត្ថិភាពតាមប្រព័ន្ធអនឡាញ ក្នុងចំណោមភាគីពាក់ព័ន្ធទាំងឡាយដូចជា សិស្សានុសិស្ស ឪពុកម្តាយ គ្រូបង្រៀន ម្ចាស់ជំនួយ មន្ត្រីរាជការ និងសាធារណជនទូទៅ និងបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់ អង្គការឆាលហ្វាន កូរ៉េ, អង្គការឆាលហ្វាន កម្ពុជា, ធនាគារ អ៊ូរី និងអង្គការបង្រៀនដើម្បីកម្ពុជា ក្នុងការពង្រឹងជំនាញដ៏សំខាន់ទាំងនេះ ក្នុងចំណោមកុមារនិងយុវជននៅប្រទេសកម្ពុជា។ លើសពីនេះទៀត ដើម្បីលើកទឹកចិត្តក្រុមគោលដៅទាំងនេះ ឱ្យទាញយកប្រយោជន៍ពីធនធាន និងឱកាសសម្រាប់ការអភិវឌ្ឍជំនាញអក្ខរកម្មឌីជីថល ហិរញ្ញវត្ថុ និងសុវត្ថិភាពតាមប្រព័ន្ធអនឡាញរបស់ពួកគេ។

To enhance awareness of digital and financial literacy, including online safety, among various stakeholders such as students, parents, teachers, donors, government officials, and the general public, while spotlighting the efforts of ChildFund Korea, ChildFund Cambodia, Woori Bank, and Teach for Cambodia in fostering these crucial skills among children and youth in Cambodia. Encouraging these target groups to capitalize on available resources and opportunities for developing their digital literacy, financial literacy, and online safety skills.

# បង្កើនសមត្ថភាពកុមារ និងយុវជនឱ្យទទួលបានជោគជ័យ ផ្នែកឌីជីថល ហិរញ្ញវត្ថុ និងសុវត្ថិភាពអនឡាញ

# Empowering Children and Youth for Digital, Financial, and Online Safety Competency.

## អក្ខរកម្មឌីជីថល
## Digital Literacy

### បង្កើនសមត្ថភាពកុមារ និងយុវជនឱ្យទទួលបានជោគជ័យ ផ្នែកឌីជីថល ហិរញ្ញវត្ថុ និងសុវត្ថិភាពអនឡាញ

### Empowering Children and Youth for Digital, Financial, and Online Safety Competency.



១ អភិវឌ្ឍខ្លួនអ្នក តាមរយៈចំណេះដឹងផ្នែកឌីជីថល
២ ចំណេះដឹងផ្នែកឌីជីថល គឺជាផែនទីបង្ហាញផ្លូវឆ្ពោះទៅរកភាពជោគជ័យ
៣ យុគ្គសម័យឌីជីថល ជាយុគរបស់អ្នក
៤ ត្រួតត្រាផ្លូវឆ្ពោះទៅរកភាពជោគជ័យ ត្រូវមានភាពឆ្លាតវៃផ្នែកឌីជីថល
៥ អក្ខរកម្មកុំព្យូទ័រ ជាច្រកផ្លូវឆ្ពោះទៅរកឱកាសការងារល្អ

1 Develop yourself through digital knowledge
2 Digital knowledge is a roadmap to success
3 The digital age belongs to you
4 Build your road to success with digital know-how
5 Computer literacy as a gateway to good job opportunities

## ចំណេះដឹងហិរញ្ញវត្ថុ
## Financial Literacy

### បណ្ដុះកុមារថ្ងៃនេះពីចំណេះដឹងហិរញ្ញវត្ថុ ជួយដល់សេដ្ឋកិច្ចជាតិសម្រាប់ថ្ងៃស្អែក

### Educate financial knowledge to children today, benefit the national economy tomorrow



១ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ មានសារៈសំខាន់សម្រាប់ជីវិត
២ សេរីភាពហិរញ្ញវត្ថុ ចាប់ផ្តើមជាមួយនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ
៣ គ្រប់គ្រងលុយរបស់អ្នក គ្រប់គ្រងជីវិតរបស់អ្នក

1 Financial literacy is essential for our life
2 Financial freedom starts with financial literacy
3 Manage your money, master your life

## សុវត្ថិភាពតាមប្រព័ន្ធអនឡាញ
## Online Safety

### បង្កើតពិភពឌីជីថលដែលមានសុវត្ថិភាពសម្រាប់កុមារ

### Make a safe digital world for children



១ គិតអំពីគ្រោះថ្នាក់ មុនពេលចែករំលែក ឬផ្ញើសារតាមប្រព័ន្ធអនឡាញ
២ ប្រាប់នរណាដែលអ្នកទុកចិត្ត បើអ្នកសង្ស័យ ឬរងការគំរាមកំហែង តាមប្រព័ន្ធអនឡាញ
៣ ប្រុងប្រយ័ត្នចំពោះការលួងលោមរបស់នរណាម្នាក់តាមប្រព័ន្ធអនឡាញ
៤ មិនគួរចែករំលែករូបថតស្រើបស្រាល ឬស្និទ្ធស្នាលអំពីខ្លួនអ្នកទៅអ្នកដទៃឡើយ

1 Be mindful of the dangers before sharing or texting online.
2 Communicate with someone you trust if you suspect or face online threats
3 Beware of someone deceiving you online
4 Do not share erotic or intimate photos of yourself with others

# អត្តសញ្ញាណរបស់គម្រោង
## Project Branding

### ស្លាកសញ្ញារបស់គម្រោង
### Project Symbol

គ្រឹះឌីជីថលយើង
Our DigiED

### គាំទ្រដោយ
### Supported by

WOORI BANK · ChildFund Korea · ChildFund Cambodia · Teach For Cambodia

### ការប្រើប្រាស់ក្តារពណ៌ Color Palette

### ការប្រើប្រាស់ទម្រង់អក្សររបស់គម្រោង Typeface

ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ អ
០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩

Khmer OS Muol Light

ក ខ

ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ អ
០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩

Khmer OS Battambang

ក ខ

A B C D E F G H I J K L M N O P Q R S T U V W X Y Z
a b c d e f g h i j k l m n o p q r s t u v w x y z
1 2 3 4 5 6 7 8 9 0
Symbol Font
! @ # $ % ^ & * ( ) _ - + = < > / ?

Fredoka

Hello I'm Font Fredoka. Icontain 6 style

- Light
- Regular
- Medium
- Semibold
- Bold

### ការប្រើប្រាស់នៅលើសម្ភារៈរបស់គម្រោង Applying project branding application














# យុទ្ធសាស្ត្របណ្ដាញ
# Channel Strategy

## បណ្ដាញប្រព័ន្ធផ្សព្វផ្សាយសង្គម

ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសិស្សានុសិស្ស មាតាបិតា គ្រូបង្រៀន និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃសមត្ថភាពឌីជីថល និងបង្ហាញអំពីគំនិតផ្តួចផ្តើមរបស់គម្រោង។ បង្កើត និងចែករំលែកមាតិកាដែលគួរឱ្យចាប់អារម្មណ៍ ដូចជាវីដេអូ ផ្ទាំងរូបភាពព័ត៌មាន និងអត្ថបទប្លុក ដែលបង្ហាញពីអត្ថប្រយោជន៍នៃចំណេះដឹងផ្នែកឌីជីថល និងសកម្មភាពផ្សេងៗនៃគម្រោងនេះដែលកំពុងជួយបង្កើនសមត្ថភាពឌីជីថលនៅក្នុងសាលារៀនកម្ពុជា។

## Social Media Channels

Use social media to connect with students, parents, teachers, and other stakeholders in Cambodia to raise awareness of the importance of digital competency and promote the project's initiatives. Create and share engaging content, such as videos, infographics, and blog posts, that showcase the benefits of digital literacy and how the project is helping to improve digital competency in Cambodian schools.

| Facebook | Telegram | YouTube | LinkedIn | TikTok |
|---|---|---|---|---|
| MoEYS Cambodia | MoEYS Cambodia | MoEYS Cambodia | MoEYS Cambodia | Woori bank cambodia |
| ChildFund Korea | Woori bank cambodia | Woori bank cambodia | ChildFund Korea | Teach For Cambodia |
| ChildFund Cambodia | Teach For Cambodia | Teach For Cambodia | ChildFund Cambodia | |
| Woori bank cambodia | | | Woori bank cambodia | |
| Teach For Cambodia | | | Teach For Cambodia | |

### Hashtag #

#Digitalliteracy
#Financialliteracy
#OnlineSafety
#ChildFundCambodia
#ChildFundKorea
#MoEYSCambodia
#woooribankcambodia
#TeachforCambodia
#Cambodia

### យុទ្ធសាស្ត្រមាតិកា

ជាមធ្យម ១ ទៅ ២ ផុសក្នុងមួយសប្តាហ៍
ប្រភេទមាតិកាចម្រុះ រួមមានផ្ទាំងរូបភាព,
អាល់ប៊ុមរូបថត, GIFs (៣ ទៅ ៦ វិនាទី) និងវីដេអូ
វីដេអូអំពីវឌ្ឍនភាពគម្រោង
ផុសអំពីសមិទ្ធផលគម្រោង
ផុសបែបអប់រំអំពីអក្ខរកម្មឌីជីថល អក្ខរកម្មហិរញ្ញវត្ថុ
និងសុវត្ថិភាពតាមប្រព័ន្ធអនឡាញ
កម្មវិធីសំណើចបែបអប់រំ
កម្មវិធីជជែកពិភាក្សាអំពីឌីជីថល

### Content Strategy

Average 1 - 2 posts per week
Variety of Medium, Still image Poster,
Photo Album, GIFs (3-6 sec) and Videos
Videos about Project progress update
Achievement Post
Education posts about digital literacy,
financial literacy, and online safety
Education Comedy Show
Digital Talkshow

## សេចក្ដីប្រកាសព័ត៌មាន

អញ្ជើញអ្នកសារព័ត៌មាន និងអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីស្វែងយល់បន្ថែមអំពីគម្រោង គោលដៅ និងផលជះគម្រោងមកលើសិស្សានុសិស្ស និងគ្រូបង្រៀនក្នុងប្រទេសកម្ពុជា។ ដាក់ចេញនូវសេចក្តីប្រកាសព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីគម្រោង និងគំនិតផ្តួចផ្តើមរបស់គម្រោង។

### បណ្ដាញព័ត៌មាន

ហ្វ្រេសញូ
ភ្នំពេញប៉ុស្ដិ៍
កោះសន្តិភាព

### ស្ថានីយ៍ទូរទស្សន៍

ទូរទស្សន៍ជាតិកម្ពុជា ទទក
ភីអិនអិន
ប៊ីធីវី
ស៊ីប៊ីៈអេស (ក្រុមហ៊ុនបណ្តាញផ្សព្វផ្សាយកម្ពុជា)
ស្ថានីយ៍ទូរទស្សន៍ រស្មីហង្សមាស

### យុទ្ធសាស្ត្រមាតិកា

ព្រឹត្តិការណ៍សារព័ត៌មានចំនួន ៤ ក្នុងរយៈពេល ៣ ឆ្នាំ
ប្រភេទមាតិកាចម្រុះ រួមមានផ្ទាំងរូបភាព, អាល់ប៊ុមរូបថត, GIFs (៣ ទៅ ៦ វិនាទី) និងវីដេអូ
វីដេអូអំពីវឌ្ឍនភាពគម្រោង
ផុសអំពីសមិទ្ធផលគម្រោង
ផុសអប់រំអំពីអក្ខរកម្មឌីជីថល អក្ខរកម្មហិរញ្ញវត្ថុ និងសុវត្ថិភាពតាមប្រព័ន្ធអនឡាញ

## Press Release

Invite journalists and other media professionals to learn more about the project, its goals, and its impact on students and teachers in Cambodia.
Issue a press release to generate media coverage for the project and its initiatives.

### Media outlet

Freshnews
Phnom Penh Post
Koh Santepheap

### TV Station

National Television of Cambodia
PNN
BTV
CBS
Hang Meas HDTV

### Content Strategy

4 press events for 3 years
Variety of Medium, Still image Poster, Photo Album, and Videos
Videos about Project progress update
Achievement Post
Education posts about digital literacy, financial literacy, and online safety

# យុទ្ធសាស្ត្របណ្តាញ (បន្ត)
# Channel Strategy (Continue)

## ផ្ទាំងប៉ាណូ និងផ្លាកសញ្ញា

ដាក់ផ្ទាំងប៉ាណូ និងផ្លាកសញ្ញានៅតាមទីតាំងយុទ្ធសាស្ត្រដែលបានជ្រើសរើសក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និងកំពត ដើម្បីផ្សព្វផ្សាយគម្រោង និងសារៈសំខាន់របស់គម្រោង។ រចនាផ្ទាំងប៉ាណូ និងផ្លាកសញ្ញាដែលគួរឱ្យទាក់ទាញ និងផ្តល់ព័ត៌មានផ្សេងៗ ក៏ដូចជាបង្ហាញសារដែលមានអត្ថន័យថា សមត្ថភាពឌីជីថលមានសារៈសំខាន់សម្រាប់ភាពជោគជ័យក្នុងសតវត្សទី ២១។

**ប្រធានបទ**
អំពីគម្រោង និងដៃគូសហការ
អក្ខរកម្មឌីជីថល
អក្ខរកម្មហិរញ្ញវត្ថុ
សុវត្ថិភាពតាមប្រព័ន្ធអនឡាញ

**ទីតាំង**
ផ្ទាំងប៉ាណូ ឬផ្លាកសញ្ញានៅទីតាំង
ចំនួន ២១ សាលារៀនគោលដៅ

## Billboard and Signage

Place billboards and signage in strategic locations throughout the selected location in Phnom Penh, Kandal and Kampot to promote the project and its importance. Design billboards and signage that are eye-catching and informative, and that convey the message that digital competency is essential for success in the 21st century.

**Topics**
About Projects and Partners
Digital Literacy
Financial Literacy
Online Safety

**Locations**
Billboard & Signage
for x 21 schools

## ព្រឹត្តិការណ៍ និងកម្មវិធីប្រកួតប្រជែងនៅសាលាគោលដៅចំនួន ២១

បង្កើត និងរៀបចំព្រឹត្តិការណ៍នៅសាលាគោលដៅចំនួន ២១ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសិស្សានុសិស្ស ឪពុកម្តាយ និងគ្រូបង្រៀនតាមរយៈកម្មវិធីសិក្សារៀនសូត្រផ្សេងៗដូចជាសិក្ខាសាលា សន្និសីទ និងការរៀបចំកម្មវិធីប្រកួតប្រជែងដើម្បីឱ្យសិស្សានុសិស្សអាចបង្ហាញជំនាញក្នុងការសរសេរកូដ ការរចនាគេហទំព័រ ការនិទានរឿងបែបឌីជីថល និងសុវត្ថិភាពតាមប្រព័ន្ធអនឡាញរបស់ពួកគេ។

**កម្មវិធីផ្សព្វផ្សាយតាមសាលាចំនួន ២១ និងការប្រកួតប្រជែងចំនួន ២ ដង**

**ការដាក់ស្តង់ដោយធនាគារ អ៊ូរី អំឡុងពេលកម្មវិធីនីមួយៗនៅតាមសាលារៀន**

**ប្រធានបទ**
អក្ខរកម្មឌីជីថល
អក្ខរកម្មហិរញ្ញវត្ថុ
សុវត្ថិភាពតាមប្រព័ន្ធអនឡាញ

**X 4 events Roadshow at 21 Schools and X 2 times competitions**

**Booth activation by Woori Bank during each event at schools**

**Topics**
Digital Literacy
Financial Literacy
Online Safety

## Events and Competitions at Selected 21 Schools

Host and Organize events at selected 21 schools to engage students, parents, and teachers with interactive learning events like workshops and conferences, organizing competition showcasing student skills in coding, web design, digital storytelling, and online safety.




## របាយការណ៍ទំនាក់ទំនងផលជះដែលគ្រប់ជ្រុងជ្រោយ វីដេអូ និងសម្ភារៈ IEC

បង្កើតរបាយការណ៍គ្រប់ជ្រុងជ្រោយ ដែលតាមដានវឌ្ឍនភាពរបស់គម្រោង និងវាយតម្លៃឥទ្ធិពលរបស់គម្រោងមកលើសិស្សានុសិស្ស និងគ្រូបង្រៀននៅកម្ពុជា។ ផលិតវីដេអូរំលេចពីផលជះរបស់គម្រោង ដោយសិស្សានុសិស្សចែករំលែកអត្ថប្រយោជន៍របស់ពួកគេ និងលោកគ្រូអ្នកគ្រូបង្ហាញពីវិធីសាស្ត្របង្រៀនដែលបានកែលម្អប្រសើរជាងមុន។ លើសពីនេះទៅទៀត បង្កើតសម្ភារៈព័ត៌មានការអប់រំ និងទំនាក់ទំនង (សម្ភារៈ IEC) ដូចជាខិត្តប័ណ្ណ ផ្ទាំងរូបភាព ផ្ទាំងរូបភាពព័ត៌មាន និងបដា ដើម្បីអប់រំសិស្សានុសិស្ស មាតាបិតា និងគ្រូបង្រៀនអំពីអក្ខរកម្មឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធិភាព។ ចែករំលែកបាយការណ៍ វីដេអូ និងសម្ភារៈ IEC ទាំងនេះជាមួយមន្ត្រីរាជការ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្ហាញពីភាពជោគជ័យរបស់គម្រោង។

## Comprehensive Impact Communication Reporting, Videos, and IEC Materials

Generate comprehensive reports tracking the project's progress and assessing its influence on students and teachers in Cambodia. Produce impactful videos highlighting the project's effects, with students sharing their benefits and teachers showcasing improved teaching methods. Additionally, develop Information, Education, and Communication (IEC) materials such as brochures, posters, infographics, and banners to educate students, parents, and teachers on digital literacy and effective technology usage. Share these reports, videos, and IEC materials with government officials, donors, and other stakeholders to demonstrate the project's success.

## តារាងពេលវេលានៃការទំនាក់ទំនង

### Communication Timeline

| | 2023 | | 2024 | | | | 2025 | | | | 2026 |
|---|---|---|---|---|---|---|---|---|---|---|---|
| | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| បណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម<br>Social Media Channels | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| សេចក្តីប្រកាសព័ត៌មាន<br>Press Release | | ■ | ■ | | ■ | | | ■ | | | ■ |
| ផ្ទាំងប៉ាណូ និងផ្លាកសញ្ញា<br>Billboard and Signage | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | |
| ព្រឹត្តិការណ៍ និងកម្មវិធីប្រកួតប្រជែងនៅសាលាគោលដៅចំនួន ២១ Events and Competitions at Selected 21 Schools | | | | ■ | ■ | | | ■ | ■ | | |
| របាយការណ៍ទំនាក់ទំនងផលជះដែលគ្រប់ជ្រុងជ្រោយ វីដេអូ និងសម្ភារៈ IEC<br>Comprehensive Impact Communication, Reporting, Videos, and IEC Materials | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |